ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា
លេខ ធ៧.០៩-០១២ ប្រក.

# ប្រ កា ស
## ស្តីពី
## សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- ប្រកាសលេខ ធ៧.០៧-១៦៣ ប្រក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំនៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩។

## ស ម្រេ ច

**ប្រការ ១ .-**

កំណត់សោហ៊ុយអាជ្ញាប័ណ្ណសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណជន ។

**ប្រការ ២ .-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្នើសុំប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណ

ប្រចាំឆ្នាំឱ្យធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម ៖

១- ទីស្នាក់ការកណ្តាល : ៥.០០០.០០០ រៀល

២- សាខា : ១.៥០០.០០០ រៀល ក្នុងមួយសាខា

**ប្រការ ៣ .-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលបើកទីស្នាក់ការកណ្តាល ឬសាខា នៅក្នុងឆ្នាំ ត្រូវបង់សោហ៊ុយ អាជ្ញាប័ណ្ណ ដូចខាងក្រោម ៖

- ក្នុងត្រីមាសទីមួយ : ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទីពីរ : ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទីបី : ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទីបួន : ត្រូវបង់មួយត្រីមាស

**ប្រការ ៤ .-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនប្រាំសែនរៀល (៥០០.០០០រៀល) នៅពេលដាក់ពាក្យសុំអាជ្ញាប័ណ្ណ ។

**ប្រការ ៥ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៦ .-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០៩

**ទេសាភិបាល**



**ជា-ចាន់តូ**

**កន្លែងទទួល**

-ដូចប្រការ៥"ដើម្បីអនុវត្ត"

- កាលប្បវត្តិ

- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"